**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រចេះ**

**ស្រុក ចិត្របុរី**

**ឃុំ សំបុក**

**លេខ:** ០៧/១៧ ឃ.ស

# ដីកា

# ស្តីពី

# ការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរិមជ្ឈការ អំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងលិខិតជម្រាបរបស់រដ្ឋបាលខេត្តក្រចេះលេខ៨១៣ ល.ក្រច ចុះថ្ងៃ១១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបញ្ឈប់ជាបន្ទាន់មិនអោយផលិតស្រានៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្នុងក្រុង ស្រុកទាំងអស់ខេត្តក្រចេះ។
- យោងលទ្ធផលសិក្ខាសាលាស្តីពី "វិធានការរួមក្នុងការបង្ការ និងទប់ស្កាត់អំពើហិង្សាលើដៃគូស្និតស្នាលដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំសំបុក ស្តីពីវិធានក្នុងការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧។

ដោយមើលឃើញថា បញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំសំបុក ដូច្នេះ ក្រុមប្រឹក្សាឃុំសំបុក

## សម្រេច

ប្រការ១-; ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សាព្រមទាំងលើកកម្ពស់សុខុមាលភាព និងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជាការរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងឃុំ សំបុក ទាំងមូល។

ប្រការ២-; ដីកានេះមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬ បង្ករការរំខាន ឬបង្កហិង្សានានា ព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជន ឬនៅទីកន្លែងមួយចំនួនក្នុងឃុំសំបុក ដែលបានកំណត់ក្នុងដីកានេះ។

ប្រការ៣-; ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ នៅក្នុងឃុំសំបុក តាមវិធីផ្សេងៗ ដូចជា ការជួបជុំបងប្អូន មិត្តភក្តិ ជាពិសេសកម្មវិធីប្រជុំ និងវេទិកាផ្សេងៗ នៅក្នុងសហគមន៍។

ប្រការ៤-; ព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត ចាស់ព្រឹទ្ធាចារ្យ និងនាយកសាលាចូលរួមក្នុងបង្កើនការអប់រំដល់ប្រជាពលរដ្ឋក្នុងសហគមន៍ សាលារៀន និងពិធីបុណ្យផ្សេងៗ។

ប្រការ៥-; បញ្ចូលកម្មវិធីការទប់ស្កាត់ អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដោយសារគ្រឿងស្រវឹងចូលទៅក្នុងកម្មវិធីវិនិយោគ ឬផែនការអភិវឌ្ឍន៍ឃុំ សំបុក។

ប្រការ៦-; ហាមផ្សព្វផ្សាយ ហាមលក់ និងហាមសេពគ្រឿងស្រវឹងនៅតាមរបងសាលារៀន វត្តអារ៉ាម សាលាឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាគារសាធារណៈរបស់រដ្ឋ។

ប្រការ៧-; ហាមផលិត និងលក់ស្រាសរដែលគ្មានច្បាប់អនុញ្ញាតិ។ ក្នុងករណីដែលបងប្អូនអាជីវករមានបំណងចង់ផលិតស្រាសរត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីថ្នាក់ស្រុក។

ប្រការ៨-; ហាមផ្សព្វផ្សាយរូបភាព ឬ ធ្វើសកម្មភាពបង្ខិតបង្ខំ ឬ ជម្រុញលើកទឹកចិត្តគ្រប់រូបភាពអោយក្មេងអាយុក្រោម១៨ឆ្នាំសេពគ្រឿងស្រវឹងនៅក្នុងសហគមន៍។

ប្រការ៩-; ហាមសេពគ្រឿងស្រវឹងដែលបង្កសំឡេងរំខានដល់អ្នកដទៃចាប់ពីម៉ោង១១យប់ឡើងទៅ និងការបង្កភាពឥតសណ្តាប់ធ្នាប់នៅទីសាធារណៈផ្សេងៗក្នុងឃុំ។ ក្នុងករណីដែលមានកម្មវិធីចាំបាច់ គឺត្រូវស្នើសុំការអនុញ្ញាត្តពីក្រុមប្រឹក្សាឃុំ។

ប្រការ១០-; ហាមលក់គ្រឿងស្រវឹងអោយជនដែលស្ថិតក្នុងស្ថានភាពស្រវឹង។

ប្រការ១១-; អាជ្ញាធរ (មេភូមិ ប៉ុស្តិ៍នគរបាល និងមេឃុំ) ត្រូវហៅអ្នកប្រព្រឹត្តផ្ទុយពីប្រការ៦, ប្រការ៧, ប្រការ៨, ប្រការ៩ និងប្រការ១០ ដើម្បីធ្វើការអប់រំ និងណែនាំដោយមានកិច្ចសន្យា។ ក្នុងករណី០៣លើក អ្នកប្រព្រឹត្តនៅតែមិនអនុវត្តតាមការណែនាំរបស់អាជ្ញាធរ នឹងត្រូវធ្វើការផាកពិន័យនៅលើកទី០៤ ជាប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ១០០.០០០(ដប់ម៉ឺន) រៀល លើកទី០៥ ចំនួន២០០.០០០(ម្ភៃម៉ឺន)រៀល ទៅ៤០០.០០០(សែសិបម៉ឺន)រៀល និងលើកទី០៦ ចំនួនចាប់ពី៨០០.០០០(ប៉ែតសិបម៉ឺន)រៀល ដល់១.០០០.០០០(មួយលាន)រៀល ឬចាត់វិធានការតាមច្បាប់ជាធរមាន។

ប្រការ១២-; ថវិកាដែលទទួលបានពីការផាកពិន័យនៅក្នុងប្រការ១១ គឺត្រូវដាក់បញ្ចូលក្នុងកញ្ចប់ថវិកាមូលនិធិឃុំ ដើម្បីប្រើប្រាស់ក្នុងការអភិវឌ្ឍឃុំ។

ប្រការ១៣-; ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅឃុំសំបុក ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៧

មេឃុំសំបុក

ខុយ_សុវណ្ណា

**ចម្លងជូន**

- សាលាស្រុកចិត្របុរី
  (ដើម្បីជូនជ្រាប)
- ក្រុមប្រឹក្សាឃុំ, ប៉ុស្តិ៍នគរបាល និងមេភូមិគ្រប់ភូមិ
  (ដើម្បីអនុវត្ត)
- ឯកសារកាលប្បវត្តិ